# សវនាការលើភ័ស្តុតាងក្នុងករណី០០២ : ថ្ងៃទី៤

*ដោយ រ៉េនឌល ឌីហ្សាល់កូ*

*ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២*

*ប្រែសម្រួលដោយ ផា ផល្លា*

នៅថ្ងៃព្រហស្បតិ៍ ទី១៩ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តសវនាការលើបញ្ហាភ័ស្តុតាង ។ នៅអំឡុងពេលសវនាការបីថ្ងៃមុន មេធាវីការពារក្តីបានកែប្រែប្រភេទឯកសារជាច្រើន ដូចជាឯកសារទូរលេខ កំណត់ហេតុអង្គប្រជុំថ្នាក់ខ្ពស់ សៀវភៅ អត្ថបទបទសម្ភាសន៍ និងប្រភពឯកសារផ្សេងទៀត ។ ដំណើរការនីតិវិធីនៅថ្ងៃព្រហស្បតិ៍នឹងបន្តទៅមុខដូចមុន ដោយមានការឆ្លើយតបរបស់ព្រះរាជអាជ្ញា និងការនិយាយឡើងវិញអំពីអំណះអំណាងជាច្រើនដែលបានដាក់ជូនសវនការនៅសប្តាហ៍មុន ។

## ការឆ្លើយតបបន្ថរបស់ព្រះរាជអាជ្ញា

សវនាការនៅថ្ងៃនេះគឺជាការឆ្លើយតបរបស់ព្រះរាជអាជ្ញាទៅកាន់អំណះអំណាងរបស់មេធាវីការពារក្តីកាលពីថ្ងៃពុធ ។ ព្រះរាជអាជ្ញាចាប់ផ្តើមដោយការពិភាក្សាពីបញ្ជីភ័ស្តុតាងបឋមដែលខ្លួនបានដាក់នៅខែមេសា ឆ្នាំ២០១១ ។ ខណៈពេលដែលមានការការកត់សម្គាល់ថា បញ្ជីនេះមិនបានលើកឡើងពីហេតុផលផ្សេងគ្នាបញ្ជាក់ថា ហេតុអ្វីបានជាភ័ស្តុតាងនោះគួរឲ្យជឿទុកចិត្តបាន និងមានជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ ព្រះរាជអាជ្ញាបានលើកឡើងបន្ថែមថា មេធាវីការពារក្តីបានបិទបាំងពីការពិត ដែលខ្លួនបានធ្វើបញ្ជីនេះ មុនពេលមានអង្គជំនុំជម្រះចេញដីកាបែងចែក ពីព្រោះដីកាបែងចែកនោះបានបណ្តាល ឲ្យមានការវាយតម្លៃម្តងទៀតទៅលើបញ្ហាដែលជាប់ពាក់ព័ន្ធ ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះរាជអាជ្ញាបានអះអាងថា ឯកសារដែលខ្លួនបានស្នើរកដើម្បីដាក់ជាភ័ស្តុតាងសុទ្ធតែមានទាក់ទងនឹងសវនាការបឋមលើករណី០០២ ហើយបញ្ជីនោះមានប្រវែងវែងដោយសារតែសវនាការបឋមមានរួមបញ្ចូលបញ្ហារចនាសម្ព័ន្ធរដ្ឋបាលនិងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាងនេះទៅទៀត ព្រះរាជអាជ្ញាបានធ្វើកំណត់សម្គាល់ឃើញថា អង្គជំនុំជម្រះបានបង្ហាញថា នឹងមានការស្រាវជ្រាវពីប្រធានបទផ្សេង ប្រសិនបើអាចទៅរួច ។

ឯកសារដែលមេធាវីការពារក្ដីរបស់ នួន ជា អះអាងថា មិនសូវជាប់ពាក់ព័ន្ធ ដូចជា ឯកសារទូរលេខជាក់លាក់មួយចំនួននោះ ព្រះរាជអាជ្ញាបានអះអាងថា ឯកសារបែបនោះអាចបង្ហាញពីវិធីសាស្ត្រទំនាក់ទំនងនឹងកម្ពុជាប្រជាធិបតេយ្យ ។ យោងទៅតាមព្រះរាជអាជ្ញា ការបង្កើតជាលំហូរព័ត៌មានទូទៅអាចបង្ហាញពីការជាប់ពាក់ព័ន្ធនឹងការចូលរួមរបស់ជនត្រូវចោទទៅនឹងសហឧក្រិដ្ឋកម្មរួម ពីព្រោះវាអាចបង្ហាញពីចំណេះដឹងនៃការអនុវត្តន៍របស់អ្នកទាំងនោះ និងផលប៉ះពាល់របស់គម្រោងនោះ នៅក្នុងប្រទេសកម្ពុជា ។

បន្ទាប់មក ព្រះរាជអាជ្ញាធ្វើកំណត់សម្គាល់ថា សាក្សីមួយចំនួនដែលនឹងត្រូវកោះហៅនៅពេលខាងមុខគឺជាអតីតកម្មាភិបាលផ្នែកទូរលេខរបស់បក្សកុម្មុយនីស្ដកម្ពុជា និងអ្នកបកស្រាយទូរលេខសម្ងាត់ ដូច្នេះសក្ខីកម្មរបស់សាក្សីទាំងនេះនឹងអាចដោះស្រាយចម្ងល់ទាក់ទងនឹងទូរលេខ ។ ជាងនេះទៅទៀត ព្រះរាជអាជ្ញាបានអះអាងថា ឈ្មោះជាច្រើនដែលមាននៅក្នុងទូរលេខ ។ ចំពោះមេធាវីការពារក្ដីរបស់ អៀង សារី បានអះអាងថា ជាបុគ្គលដែលមិនមានគេស្គាល់ត្រូវបានយកទៅពិភាក្សា និងបកស្រាយនៅក្នុងដីកាដំណោះស្រាយ ។ ជាឧទាហរណ៍ "បង ញឹម" សំដៅទៅលើលេខាបក្ស ពាយ័ព្យរបស់បក្សកុម្មុយនីស្ដកម្ពុជា រស់ ញឹម ដែលត្រូវបានចាប់ខ្លួននិងបញ្ជូនទៅមន្ទីរ ស-២១ ហើយចម្លើយសារភាពរបស់គាត់ត្រូវបានដាក់នៅក្នុងសំណុំឯកសារ ។ ព្រះរាជអាជ្ញាបានសង្ខេបអំណះអំណាងនេះថា "ការត្រួតពិនិត្យ" ធម្មតាទៅលើសំណុំឯកសារអាចធ្វើឲ្យមានតម្លាភាពក្នុងការបកស្រាយថា ហេតុអ្វីបានជាឯកសារបែបនេះ មានជាប់ពាក់ព័ន្ធទៅនឹងបុគ្គលដែលមានឈ្មោះនៅក្នុងបញ្ជី ។

ព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះគួរតែធ្វើការសន្មត់ចំពោះការទទួលយកឯកសារដែលត្រូវបានដាក់ជាភស្តុតាងនៅក្នុងសំណុំរឿង០០១ ។

ព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារជាច្រើនទៀត ត្រូវតែទទួលការត្រួតពិនិត្យជាមួយនឹងបរិបទ ។ អាស្រ័យហេតុនេះទើបព្រះរាជអាជ្ញាព្យាយាមបញ្ចូលភស្តុតាងឯកសារជាច្រើននេះ ។ យោងទៅតាមព្រះរាជអាជ្ញា បន្ទាប់ពីត្រួតពិនិត្យឃើញថា ឯកសារជាច្រើនដូចជា ការផ្ញើទូរលេខចូលគ្នាអាចបង្ហាញពីលំដាប់ព្រឹត្តិការណ៍ និងនាំទៅរកឯកសារផ្សេងទៀត ។

បន្ទាប់មក ព្រះរាជអាជ្ញាបានបង្ហាញឯកសារមួយចំនួននៅក្នុងបន្ទប់សវនការដោយអះអាងថា ឯកសារទាំងនោះ គឺជាឯកសារចម្លងពីសំណៅដើមដែលមានរក្សានៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយសាក្សីអាចពិនិត្យទៅលើឯកសារទាំងនោះ ប្រសិនបើចាំបាច់ ។ ព្រះរាជអាជ្ញាបានធ្វើកំណត់សម្គាល់ថា សាក្សីបានពិនិត្យទៅលើឯកសារខ្លះ ហើយសាក្សីក្រោយទៀតនឹងបញ្ជាក់ពីឯកសារជាច្រើនទៀតព្រមទាំងបញ្ជាក់ពីអក្សរសរសេរដោយដៃនិងហត្ថលេខាទៀតផង ។

ដើម្បីបញ្ជាក់ពីឯកសារ ព្រះរាជអាជ្ញាបានផ្តល់ឧទាហរណ៍មួយពីទូរលេខដែលផ្ញើពីភ្នំពេញទៅទីក្រុងហុងកុងដោយបក្សកុម្មុយនីស្តកម្ពុជា ។ ទូរលេខនេះបានប្រាប់ស្ត្រីម្នាក់ឈ្មោះ ផល វ៉ា ឲ្យត្រឡប់មកភ្នំពេញជាមួយប្តីឈ្មោះ អៀង សុខ ។ បន្ទាប់មក ព្រះរាជអាជ្ញាបានធ្វើកំណត់សម្គាល់ពីឯកសារអ្នកទោសស-២១ ដែលបង្កើតឡើងនៅប៉ុន្មានសប្តាហ៍ក្រោយមកដែលមានឈ្មោះ ផល វ៉ា និង អឿង សុខ ។ ដើម្បីបញ្ជាក់ពីចំណុចនេះ ព្រះរាជអាជ្ញាបានបង្ហាញរូបថតដែល ផល វ៉ា ញញឹមពេលកំពុងអង្គុយនៅតុធ្វើការនៅហុងកុង និងរូបថតរបស់គាត់នៅក្នុងសម្លៀកបំពាក់អ្នកទោស ដែលមានលេខសម្គាល់នៅស-២១ ។

ចំពោះចំណុចនេះ ព្រះរាជអាជ្ញាគូសបញ្ជាក់ឲ្យដឹងថា ខ្លួនមានឧទាហរណ៍ជាច្រើនទៀតទាក់ទងនឹងឯកសារស្រដៀងគ្នា ហើយនឹងអាចបកស្រាយពន្យល់ស្រដៀងគ្នាបាន ។

## មតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពី ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សារណាហើយ ជាមួយគ្នានោះដែរ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ឯកសារទំនាក់ទំនងផ្សេងៗគ្នាដូចជា ទូរលេខ និងឯកសារផ្សេងទៀតបង្ហាញថាមានប្រតិបត្តិការតាមរចនាសម្ព័ន្ធឋានុក្រមយ៉ាងច្បាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយព័ត៌មានទាំងនេះ គឺមានទំនាក់ទំនងយ៉ាងច្បាស់ទៅនឹងសំណុំរឿង០០២ ។

ចំពោះការប្រមូល និងការរក្សាឯកសារ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើកំណត់សម្គាល់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានចំណាយពេលជាច្រើនឆ្នាំដើម្បីប្រមូល និងពិនិត្យទៅលើឯកសារខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៩៥មក ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបន្តទៀតថា បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាទាំងអស់ជាប់រវល់នឹងការស្វែងរកអាហារ ជាជាងប្រមូលឯកសារទាក់ទងនឹងខ្មែរក្រហម ។ ដូច្នេះ យើងមិនអាចកំណត់ពីការរក្សាឯកសារឲ្យច្បាស់លាស់ទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ប្រសិនបើមានចម្ងល់ទៅលើព័ត៌មានណា យើងអាចហៅនិរសារបក្សកុម្មុយនីស្តកម្ពុជាមកធ្វើសក្ខីកម្ម ពីព្រោះនិរសាជាទូទៅមានភាពស្មោះត្រង់នឹងមេដឹកនាំរបស់ខ្លួន ។

## មេធាវីការពារក្តីរបស់ នួន ជា

បន្ទាប់មក មេធាវីការពារក្តី នួន ជា បានផ្តល់យោបល់បន្ថែម ប៉ុន្តែយោបល់ភាគច្រើនដែលបានលើកឡើងនៅពេលនេះ គឺដូចនឹងការលើកលើងពីពេលមុនដែរ ។ មេធាវីការពារក្តីលើកឡើងម្តង

ទៀតពីជំហររបស់ខ្លួនថា នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ ត្រូវតែមកផ្តល់សក្ខីកម្មមុនពេលនឹងទទួលយកឯកសារទាំងអស់ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេធាវីការពារក្តីក៏បានឆ្លើយតបទៅនឹងអំណះអំណាងរបស់ព្រះរាជអាជ្ញាដែលថា ឯកសារដែលបានដាក់ជូនអង្គជំនុំជម្រះមិនមានទំនាក់ទំនងគ្នា ។ មេធាវីការពារក្តីបានអះអាងថា ការសង្កត់ធ្ងន់ទៅលើការដាក់ភ័ស្តុតាងគួរតែផ្តោតទៅលើពេលវេលាមុនរបបកម្ពុជាប្រជាធិបតេយ្យដែលពាក់ព័ន្ធនឹងការជម្លៀសលើកទីមួយ ពីព្រោះវាជាប្រធានបទរបស់សំណុំរឿង០០២ ។ មេធាវីការពារក្តីបានលើកឡើងទៀតថា វាគឺជាការព្រួយបារម្ភមួយដែលព្រះរាជអាជ្ញា បានព្យាយាមប្រើប្រាស់ឯកសារដែលមិនជាប់ពាក់ព័ន្ធមកដោះស្រាយនឹងប្រធានបទដែលត្រូវបានដកចេញពីករណីទីមួយរបស់សំណុំរឿង០០២ ឧទាហរណ៍ភ័ស្តុតាងចោទប្រកាន់ពីការបោសសម្អាតផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៧៧ និង១៩៧៨ ។

មេធាវីការពារក្តីបានស្នើជាថ្មីម្តងទៀតថា ឯកសារដើមមួយចំនួនគួរតែរក្សានៅក្នុងដៃរបស់មេធាវីការពារក្តី ដើម្បីឲ្យក្រុមមេធាវីការពារក្តីអាចប្រៀបធៀបវានឹងឯកសារចម្លងបច្ចុប្បន្ន ។ មេធាវីការពារក្តីក៏បានបដិសេធផងដែរ ទាក់ទងទៅនឹងការប្រើប្រាស់ឯកសារចម្លងដោយមិនមានការពិនិត្យទៅលើឯកសារដើម ។ មេធាវីការពារក្តីបន្តថា ព្រះរាជអាជ្ញាទទួលយកឯកសារដោយមិនត្រួតពិនិត្យពីព្រោះបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ យើងអាចបង្កើតឯកសារមិនពិតដែលបញ្ជាក់ថា នួន ជា និងអ្នកដទៃមានទោស ។

## មេធាវីការពារក្តី អៀង សារី

មេធាវីការពារក្តី អៀង សារី បានប្រើឱកាសនេះដើម្បីលើកឡើងម្តងទៀតពីការបដិសេធនឹងឯកសារមួយចំនួនដូចជា សៀវភៅនិងបទសម្ភាសន៍ ឧទាហរណ៍អត្ថបទដែលសរសេរដោយអ្នកកាសែតឈ្មោះ អេលីហ្សាប៊ែត ប៊ែកឃើ ។ អត្ថបទបែបនេះ ជាពិសេសការដកស្រង់សម្តីរបស់ អៀង សារី និងជនត្រូវចោទផ្សេងទៀតមិនអាចបញ្ជាក់ថាត្រឹមត្រូវនោះទេ ដូច្នេះគួរតែដកចេញ ប្រសិនបើអ្នកនិពន្ធមិនមកផ្តល់សក្ខីកម្ម ។

មេធាវីការពារក្តីបានអះអាងបន្ថែមថា គ្រាន់តែភ័ស្តុតាងមួយចំណុចដែលត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿង ប៉ុន្តែដាក់យោងនៅក្នុងដីកាដំណោះស្រាយ យើងមិនអាចយកភ័ស្តុតាងនេះរួមបញ្ចូលភ័ស្តុតាងនេះទៅក្នុងពេលកាត់សេចក្តីទេ ពីព្រោះដំណាក់កាលអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះលើអង្គសេចក្តីមានភាពខុសគ្នា ។ ប្រសិនបើវាដូចគ្នា នោះការបើកសវនការលើភស្តុតាងនឹងក្លាយទៅជាការខាតពេលឥតប្រយោជន៍ ។

## មេធាវីការពារក្តី ខៀវ សំផន

មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងម្តងទៀតការបដិសេធរបស់ខ្លួនទៅនឹងរបាយការណ៍ព័ត៌មាន និងឯកសារដែលប្រទេសស៊ុយអែតបានប្រមូលទាក់ទងនឹងខ្មែរក្រហម ។ មេធាវីការពារក្តីបានបញ្ជាក់ថា ព្រះរាជអាជ្ញាគួរតែបកស្រាយបញ្ជាក់ថា រដ្ឋាភិបាលស៊ុយអែតទទួលបានឯកសារពីអ្នកណាមុនពេលដាក់បញ្ចូលឯកសារនោះ ។ ប្រសិនបើមិនមានព័ត៌មានបកស្រាយបែបនេះទេ ឯកសារនោះគួរតែត្រូវបានបដិសេធ ។

## ការឆ្លើយបតរបស់ព្រះរាជអជ្ញា

បន្ទាប់មក ព្រះរាជអាជ្ញាបានធ្វើការឆ្លើយតបពីការបដិសេធប្រឆាំងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ៩ ។ ឯកសារទាំងនេះរួមមាន សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់បក្សកុម្មុយនីស្តកម្ពុជាដូចជាការផ្សព្វផ្សាយតាមវិទ្យុ សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍នៅក្នុងព័ត៌មានអន្តរជាតិដែលធ្វើឡើងដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងឯកសារស្រដៀងគ្នាផ្សេងទៀត ។

ព្រះរាជអាជ្ញាបានចាប់ផ្តើម ដោយពិភាក្សាទៅលើរបាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេសដែលជាភ្នាក់ងាររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ការបកប្រែព័ត៌មានបច្ចុប្បន្ន និងការអធិប្បាយនៅក្នុងសុន្ទរកថានយោបាយបរទេស ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រភពព័ត៌មានផ្សេងទៀត ។ ព្រះរាជអាជ្ញាបានលើកឡើងថា របាយការណ៍ពីសេវាផ្សព្វផ្សាយព័ត៌មានបរទេស ទាក់ទងនឹងសំណុំរឿង០០២ គឺផ្អែកទៅលើការផ្សព្វផ្សាយតាមវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយយើងអាចស្វែងរកបាននៅក្នុងប្រព័ន្ធអ៊ីនធើណែត និងនៅក្នុងការសាកលវិទ្យាល័យហារើត ។

ប្រភេទឯកសារបន្ទាប់ដែលព្រះរាជអាជ្ញាបានលើកឡើងរួមមានសេចក្តីថ្លែងការណ៍ និងសេចក្តីប្រកាសព័ត៌មានដែលចេញដោយក្រសួងការបរទេសរបបកម្ពុជាប្រជាធិបតេយ្យ ។ ព្រះរាជអាជ្ញាបានឲ្យដឹងថា សេចក្តីថ្លែងការណ៍បែបនេះមានសារសំខាន់ ពីព្រោះសេចក្តីថ្លែងរួមមានព័ត៌មានដូចនឹងរបាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេស ដូច្នេះវាអាចបង្ហាញពីភាពត្រឹមត្រូវរបស់ប្រភពឯកសារទាំងពីរ ។ ព្រះរាជអាជ្ញាក៏បានប្រៀបធៀបសេចក្តីថ្លែងការណ៍ដែលបានដកស្រង់ចេញពីរបាយការណ៍សេវាផ្សព្វផ្សាយព័ត៌មានបរទេសថា ដូចទៅនឹងសេចក្តីប្រកាសព័ត៌មានដែលផ្សព្វផ្សាយនៅក្នុងវិទ្យុ ។ ព្រះរាជអាជ្ញាបានបន្តទៀតថា ឯកសារទាំងពីរមាន“ភាពស្រដៀងគ្នា” ដូច្នេះយើងមិនចាំបាច់កោះហៅអ្នកនិពន្ធអត្ថបទរបស់សេវាផ្សព្វផ្សាយព័ត៌មានបរទេសទេ ពីព្រោះរបាយការណ៍នោះមានភាពត្រឹមត្រូវ និងជឿទុកចិត្តបាន ។

ព្រះរាជអាជ្ញា បានបន្តនូវការបកស្រាយពីវិធីសាស្ត្ររាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេស ដោយលើកឡើងថា របាយការណ៍នោះមានរួមបញ្ចូលប្រតិចារិតនៃការផ្សព្វផ្សាយ តាមវិទ្យុដែលអាចបញ្ជាក់ពីយុទ្ធសាស្ត្ររបស់សហរដ្ឋអាមេរិក (រួមបញ្ចូលទាំងកម្ពុជាផងដែរ) ។ ព្រះរាជអាជ្ញាបានអះអាងថា របាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេស បានបង្ហាញពី«អតីតកាលដ៏មានតម្លៃ» ហើយបន្តអានរបាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេសពីឆ្នាំ១៩៧៥ ថាខ្មែរក្រហមបានប្រកាសថា «ត្រូវតែសម្លាប់»អតីតមេដឹកនាំរបប លន់ នល់ ដែលត្រូវបានគេហៅថា «ជនក្បត់កំពូល» ។ សេចក្តីថ្លែងការណ៍នោះមានហត្ថលេខារបស់ ខៀវ សំផន ។ ជាងនេះទៅទៀត របាយការណ៍ផ្សេងទៀតនៅពេលនោះបានបញ្ជាក់ទៀតថា បុគ្គលទាំងប្រាំពីររូបនឹងត្រូវយកទៅសម្លាប់បន្ទាប់ពីនោះ ។ ជាមួយគ្នានោះដែរ ព្រះរាជអាជ្ញា ក៏បានអះអាងឲ្យមានទំនុកចិត្តទៅលើរបាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេស ។

បន្ទាប់មក ព្រះរាជអាជ្ញាបានពិភាក្សាពីរបាយការណ៍វិទ្យុស្រដៀងគ្នាដែលចេញដោយសាព័ត៌មានប៊ីប៊ីស៊ី ហើយបានធ្វើកំណត់សម្គាល់ពីភាពស្រដៀងគ្នារបស់របាយការណ៍នេះទៅនឹងរបាយការណ៍សេវាផ្សព្វផ្សាយព័ត៌មានបរទេស និងជំរុញឲ្យមានការជឿទុកចិត្តទៅលើប្រភពព័ត៌មាន ។

ជាងនេះទៅទៀត ព្រះរាជអាជ្ញាបានត្រឡប់ទៅនិយាយពីបញ្ហាភស្តុតាងទូទៅដោយលើកឡើងថា នៅខែមេសា ឆ្នាំ២០១១ ព្រះរាជអាជ្ញាបានដាក់ឯកសារ២០ ទាក់ទងនឹងភស្តុតាងដែលបានស្នើទៅអង្គជំនុំជម្រះដោយមានការបកស្រាយទៅលើភស្តុតាងនីមួយៗ និងការពន្យល់ពីភាពជាប់ពាក់ព័ន្ធគ្នារបស់ឯកសារនីមួយៗដោយយោងទៅដីកាដំណោះស្រាយ ។ ព្រះរាជអាជ្ញាបាននិយាយម្តងទៀតថា ភស្តុតាងទាំងអស់ ដែលបង្ហាញពីរចនាសម្ព័ន្ធទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជាមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងរចនាសម្ព័ន្ធបញ្ជា និងគោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជាជាប្រធានបទដែលត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង០០២ ។ ព្រះរាជអាជ្ញាបានបន្តទៀតថា ការវិភាគយ៉ាងល្អិតល្អន់របស់ខ្លួន ដែលបានផ្តល់ឲ្យអង្គជំនុំជម្រះ ធ្វើឲ្យភស្តុតាងដែលបង្ហាញលើកទីមួយអាចទទួលយកបាន និងអាចធ្វើឲ្យមេធាវីការពារក្តីទាមទារឲ្យមានការដាក់បន្ទុកទៅលើព្រះរាជអាជ្ញាវិញ ។

ចំពោះការទាមទារម្តងហើយម្តងទៀតពីសំណាក់មេធាវីការពារក្តីរបស់ នួន ជា នូវឯកសារដើមនោះ ព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចថា អង្គជំនុំជម្រះនឹងទទួលយកឯកសារចម្លងជាជាងឯកសារដើម ពីព្រោះវាគឺជារឿង«មិនសមហេតុសមផល»នឹងការចំណាយពេលឥតប្រយោជន៍ដែលព្រះរាជអាជ្ញាត្រូវបង្ហាញឯកសារដើមគ្រប់ចំណុច ។

ទាក់ទងនឹងឯកសារបក្សកុម្មុយនីស្តកម្ពុជាដែលមេធាវីការពារក្តីបានស្នើថាប្រហែលជាការបង្កើតឡើង ឆ្លើយតបទៅវិញព្រះរាជអាជ្ញាបានអះអាងថា នេះគឺជាសម្មតិកម្មធម្មតាដែលលើកឡើងដើម្បីមិនមានការបង្ហាញភស្តុតាងច្បាស់លាស់ ។ ជាងនេះទៅទៀត ប្រសិនបើឯកសារមួយជាការបង្កើតឡើង ឬក៏ជាការចម្លងក្លែងក្លាយ នោះជនត្រូវចោទប្រាកដជាដឹងហើយនឹងធ្វើការលើកឡើងពីចំណុចនេះ ប៉ុន្តែបច្ចុប្បន្នក្រៅពីការទាមទាររកឯកសារដើមរបស់ នួន ជា គឺមិនមានអ្វីផ្សេងទៀតទេ ។

លើសពីនេះទៅទៀត ព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា គឺអាចជឿទុកចិត្តបាននៅពេលដែលយើងពិនិត្យមើលជារួម ពីព្រោះឯកសារនីមួយៗតែងតែមានជាប់ពាក់ព័ន្ធគ្នា ។ ព្រះរាជអាជ្ញាបានឲ្យដឹងទៀតថា អង្គជំនុំជម្រះបានអញ្ជើញសាក្សីដែលជាតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកដំណើរការទូរលេខរបស់បក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងបុគ្គលិកផ្នែកបោះពុម្ពដែលអាចបង្ហាញពីបញ្ហាទង់បដិវត្តន៍ដែលមេធាវីការពារក្តីបានធ្វើការប្រឆាំង ។

នៅទីបញ្ចប់ ព្រះរាជអាជ្ញានៅតែអះអាងថា "គ្រប់ឯកសារ" ដែលខ្លួនបានដាក់ គឺមានជាប់ពាក់ព័ន្ធគ្នា ដូច្នេះវាសាកសមនឹងដាក់បញ្ចូលជាភស្តុតាង ។ ចំពោះការទាមទាររបស់មេធាវីការពារក្តីឲ្យនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ មកផ្តល់សក្ខីកម្ម ព្រះរាជអាជ្ញាបានអះអាងថា មេធាវីការពារក្តីមិនមានសិទ្ធិទាមទារឲ្យ ឆាំង យុ មកផ្តល់សក្ខីកម្ម ដោយបានបញ្ជាក់ថា មេធាវីការពារក្តីធ្វើនេះគឺដើម្បី "ចង់និយាយជាមួយ ឆាំង យុ នៅក្នុងបន្ទប់សវនាការប៉ុណ្ណោះ" ។

ទាក់ទងទៅនឹងការទាមទារម្តងហើយម្តងទៀតឲ្យមានឯកសារដើម ព្រះរាជអាជ្ញាបានអះអាងថា នួន ជា និងជនត្រូវចោទផ្សេងមិនត្រូវតម្រូវដោយច្បាប់ឲ្យធ្វើជាអ្នកវាយតម្លៃថា ឯកសារណាមានភាពច្បាស់លាស់ និងត្រឹមត្រូវទេ ។ អ្នកទាំងនោះ ក៏ដូចជាអ្នកដទៃទៀតដែរ គឺអាចត្រឹមតែអាចផ្តល់យោបល់ទៅលើឯកសារនៅក្នុងតុលាការប៉ុណ្ណោះ ។ ជាងនេះទៅទៀតព្រះរាជអាជ្ញាបានអះអាងថា ខ្លួននឹងគ្រប់គ្រងទៅលើដំណើរដែល នួន ជា ត្រួតពិនិត្យទៅលើឯសាររាប់ពាន់នៅក្នុងតុលាការ បន្ទាប់មកកំនត់ថា ចំណុចមួយណាត្រឹមត្រូវ ។

ព្រះរាជអាជ្ញាបានព្រមានថា ប្រសិនបើអង្គជំនុំជម្រះធ្វើតាមសំណើរបស់មេធាវីការពារក្តី នោះវានឹងត្រូវចំណាយពេលជាច្រើន ហើយអង្គជំនុំជម្រះនឹងត្រូវត្រួតពិនិត្យលើភស្តុតាងដដែលៗ និងមិនមានសារៈសំខាន់ ។ ចំពោះដំណើរការដ៏ស្មុគ្រស្មាញនេះព្រះរាជអាជ្ញាបានផ្តល់យោបល់ថា អង្គជំនុំជម្រះគួរតែយកគម្រាប់តាមតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដែលបាន« ធ្វើការសន្និដ្ឋានទៅលើការទទួលភស្តុតាង» តាមទ្រឹស្តីការវាយតម្លៃដោយសេរីទៅលើភស្តុតាង ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា ការសន្និដ្ឋាននេះមានសារសំខាន់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ពីព្រោះបទឧក្រិដ្ឋមានចំនួនច្រើនមានការពាក់ព័ន្ធជាច្រើន

និងរចនាសម្ព័ន្ធគ្រប់គ្រងមានជាប់នឹងការបង្ហាញពីការអនុវត្តដោយផ្ទាល់របស់ជនត្រូវចោទ ទៅលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ។

ជាសង្ខេបព្រះរាជអាជ្ញាបានធ្វើអំណាងថា ភស្តុតាងឯកសារថ្មីៗមានសារៈសំខាន់ជាពិសេស ពីព្រោះវាមិនមានការផ្លាស់ប្តូរទៅតាមពេលវេលាទេ. ព្រះរាជអាជ្ញាបញ្ជាក់ថា វាមានសារៈសំខាន់ក្នុងការរួមបញ្ចូលគ្រប់ភស្តុតាង ពីព្រោះឯកសារទាំងនោះ អាចបង្ហាញពី«លំនាំភស្តុតាង»ដែលអាចបង្ហាញពីទោសកំហុសរបស់ជនត្រូវចោទ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា វាមិនមានជាការលាក់«ម្ជុល» នៅក្នុង«ចំបើង» ដែលជាឯកសារមិនជាប់ពាក់ព័ន្ធ ។ ឯកសារទាំងអស់មាន«ម្ជុល»ជាច្រើន ដែលអាចបង្ហាញពីទោសកំហុសរបស់ជនត្រូវចោទ ។

## *សេចក្តីឆ្លើយតបរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី*

ភាគីដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់យោបល់ទាក់ទងទៅនឹងការជំទាស់របស់មេធាវីការពារក្តី និងផ្តល់ការគាំទ្រដល់ភាគីព្រះរាជអាជ្ញា ។ មេធាវីប្រឹក្សារបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា សម្រាប់ឯកសារនៅចំពោះមុខតុលាការ ការផ្តិតមេដៃកម្រយកមកប្រើប្រាស់ ហើយសារទូរលេខគឺស្ថិតនៅក្នុងសណ្ឋានដូចមុនដដែលដោយគ្មានការប្រែប្រួលអ្វីទេ ។ ដូច្នេះ ទោះបីជាប្រើប្រាស់វិធីដែលពេញនិយមបំផុត ដើម្បីបញ្ជាក់ពីភាពពិតរបស់ឯកសារនៅប្រទេសកម្ពុជាក៏ដោយ មេធាវីប្រឹក្សាបានបញ្ជាក់ថា ការកំណត់ថា ឯកសារណាមួយជាឯកសារពិតនោះមិនមែនចេះតែអាចធ្វើបាននោះទេ ។ មេធាវីដើម្បីបណ្តឹងរដ្ឋប្បវេណីបានបន្តរថា បើសិនជាភាគីការពារក្តីមានការសង្ស័យថាឯកសារណាមួយជាឯកសារក្លែងក្លាយនោះ មេធាវីគួរតែនិយាយពីឯកសារនោះដោយដាក់ដោយឡែក ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកពីក្រុមការពារក្តីរបស់ អៀង សារី ថា ជំទាស់«ប្រាំដែល»ទៅនិងឧបសម្ព័ន្ធនីមួយៗ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា មេធាវីការពារក្តីមានចរិក«មានះ»ក្នុងការជំទាស់ទៅនឹងឯកសារនោះ ការធ្វើដូច្នេះ គឺជាការរំលោភនូវសេចក្តីសម្រេចនិងជាការខ្ជះខ្ជាយពេលវេលា ។ ការនិយាយបែបនេះធ្វើឲ្យមេធាវីរបស់ នួន ជា បានអះអាងថា ការបកស្រាយរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺជា«ការតវ៉ាដោយបំពាន» ដែលការបកប្រែជាភាសាខ្មែរហាក់បីដូចជាមិនគួរសមទាល់តែសោះ ។

ចៅក្រម និល ណុន បានអះអាងភ្លាមថា ការបកប្រែបែបនេះមិនត្រឹមត្រូវទេ ហើយចៅក្រមបានរំលឹកទៅគ្រប់ភាគីទាំងអស់ថា មិនត្រូវប្រើពាក្យមិនសមរម្យនៅក្នុងតុលាការទេ ។ ការដែលនិយាយបែបនេះ ធ្វើឲ្យអ្នកចូលរួមសើចដែលធ្វើឲ្យរសាយការហត់នឿយតាមពីព្រឹកមកផង ។

ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការសន្និដ្ឋានដោយបញ្ជាក់ថា ការជំទាស់«ដដែលជាដដែល» ចំពោះឧបសម្ព័ន្ធទីមួយរហូតដល់ទីប្រាំដោយភាគីការពារក្តីមានផលប្រយោជន៍មួយ គឺថា «បន្តិចម្តងៗ» ការជំទាស់នោះនឹងក្លាយជាការតវ៉ា«ដែលមិនសមហេតុផល» ដូចជាការអះអាងថា ឯកសារទាំងអស់សុទ្ធតែក្លែងក្លាយជាដើម ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងទៀតថា ការអះអាងដោយមិនសមហេតុផលបែបនេះ គឺគ្រាន់តែចង់ដឹងអំពីភាពដែលអាចពឹងពាក់បាននៃឯកសារប៉ុណ្ណោះ ។

ក្រោយពីភាគីដើមបណ្តឹងរដ្ឋប្បវេណីនិយាយចប់ ភាគីការពារក្តីនីមួយៗត្រូវបានផ្តល់ឱកាសដើម្បីធ្វើសេចក្តីថ្លែងជំទាស់ទៅនិងឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ១-៥ ។

## មេធាវីការពារក្តី នួន ជា ឆ្លើយតបចុងក្រោយទាក់ទងទៅនឹងឧបសម្ព័ន្ធ១-៥

ក្រុមការពារក្តីរបស់ នួន ជា បានផ្តល់ការសង្ខេបអំពីអំណះអំណាងរបស់ខ្លួន ក្នុងអំឡុងពេលពេញមួយសប្តាហ៍កន្លងមកនេះ ។ ទីមួយ មេធាវីការពារក្តីបានអះអាងថា ខ្លួនមិនមានជំហរប្រឆាំងរាល់ឯកសារទាំងអស់ទេ អង្គជំនុំជម្រះគួរតែផ្តោតទៅលើឯកសារដែលអាចពឹងពាក់បានទាក់ទងទៅនឹងប្រធានបទដែលបានរៀបរាប់នៅក្នុងតំណាក់កាលដំបូងនៃដំណើរការសវនាការ ។ ទីពីរ មេធាវីប្រឹក្សាអះអាងថាអ្វីដែលមិនត្រូវការគឺ«ដំណើរប្រវត្តិសាស្ត្រ»នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ការប្រើប្រាស់ន័យធៀបអំពីម្ហូល និងចំបើងដែលប្រើដោយមេធាវីរបស់ អៀង សារី និងបង្កើតឡើងដោយព្រះរាជអាជ្ញា មេធាវីការពារក្តីបានអះអាងថា អ្វីដែលចាំបាច់នៅក្នុងសំណុំរឿងគឺ «ម្ជុលតិច» និង«អំបោះច្រើន»ដែលមានន័យថា ត្រូវយកតែភស្តុតាងណាដែលចាំបាច់ចំពោះតែករណី០០២ទៅបានហើយ ។

មេធាវីការពារក្តីរបស់ នួន ជា បានធ្វើការអះអាងចុងក្រោយដោយទាមទាឲ្យលោក ឆាំង យុ ចូលមកធ្វើសក្ខីកម្មនៅក្នុងបន្ទប់សវនាការ ។ មេធាវីការពារក្តីបញ្ជាក់ថា ភាគីរបស់ខ្លួនធ្លាប់អះអាងថា តុលាការនេះមិនអាចដំណើរការបានទេ បើសិនជាគ្មានវត្តមានរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ហើយពេលនេះគឺថា តុលាការនេះមិនអាចដំណើរការបានទេបើសិនជាគ្មានលោក ឆាំង យុ ។ មេធាវីការពារក្តីអះអាងថា សក្ខីកម្មរបស់លោក ឆាំង យុ មានភាពច្បាស់លាស់ព្រោះបើសិនជាគ្មានការស្រាវជ្រាវរបស់លោកទេ «នោះក៏គ្មានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»ដែរ ។ ចុងក្រោយមេធាវីការពារក្តីបានអះអាងថា លោក ឆាំង យុ គឺ«អនុគ្រោះយើងដោយសារវត្តមានរបស់លោក» ក្នុងនាមជា«បុរសដ៏ល្អម្នាក់ចំពោះការងាររបស់លោក» ។

មេធាវីជាតិរបស់ នួន ជា បានបន្ថែមទៀតថា នួន ជា ចង់មើលឯកសារដើមរបស់ទស្សនាវដ្ដីទង់បដិវត្តន៍ និងកូនសៀវភៅយុវជនបដិវត្តន៍ និងឯកសារពាប់ពាន់ផ្សេងទៀតនៅក្នុងសំណុំរឿង ។ ការស្នើនេះមិនត្រូវពន្យាពេលទេ តែត្រូវ“ស្វែងរកការពិត និងស្វែងរកយុត្តិធម៌” ។

## ក្រុមការពារក្ដីរបស់ អៀង សារី ឆ្លើយតបចុងក្រោយទាក់ទងទៅនិងឧបសម្ព័ន្ធ១-៥

មេធាវីការពារក្ដីរបស់ អៀង សារី ចាប់ផ្ដើមធ្វើការសង្ខេបដោយប្រឆាំងភ្លាមៗទាក់ទងទៅនឹងសេចក្ដីថ្លែងរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីកាលពីព្រឹកមិញ ។ មេធាវីការពារក្ដីនិយាយថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែខ្ជះខ្ជាយពេលវេលា ហើយក៏បានធ្វើការរំលឹកទៅអង្គជំនុំជម្រះ និងគ្រប់ភាគីទាំងអស់ថា ភាគីព្រះរាជអាជ្ញាជាអ្នកស្នើឲ្យមានសវនាការពិភាក្សាអំពីភស្តុតាងមុនគេ ។ ក្រោយមកមេធាវីការពារក្ដីបានបញ្ជាក់ថា “ការជំទាស់សំខាន់”របស់ខ្លួនគឺថា ព្រះរាជអាជ្ញាបានស្នើឲ្យដាក់ឯកសារទាំងអស់ដែលខ្លួនបានស្នើចូលជាភស្តុតាងភ្លាមៗ ជាជាងចាំមើលស្ថានភាពជាក់ស្ដែងសិន ។ ក្រោយមកមេធាវីការពារក្ដីបានរំលឹកទៅអង្គជំនុំជម្រះនិងគ្រប់ភាគីទាំងអស់ថា មិនចាំបាច់ដាក់ឯកសារណាមួយធ្វើជាភស្តុតាងមុននឹងសួរសំណួរទេ ។ មេធាវីប្រឹក្សាបានដកស្រង់នូវអ្វីដែលអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា មេធាវីការពារក្ដីអាចជំទាស់ទៅនឹងឯកសារក្នុងអំឡុងពេលនៃដំណើរការនេះ ដើម្បីតវ៉ាជាមួយនឹងភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលមេធាវីការពារក្ដីអាចចោទថាកំពុងតែខ្ជះខ្ជាយពេលវេលា ។

ប្រធានបទដែលត្រូវយកមកនិយាយបន្ទាប់ដោយមេធាវីការពារក្ដីរបស់ អៀង សារី គឺអំពីករណី ដួលីក នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលកាលនោះមេធាវី ម៉ៃឃើល ខាណាវ៉ាស់ គឺជាមេធាវីប្រឹក្សា ។ មេធាវី ខាណាវ៉ាស់ បានបញ្ជាក់ថា នៅក្នុងករណីនោះ តុលាការបានសម្រេចចិត្តដាក់ដោយឡែកពីគ្នា៦០-១០០ដងទាក់ទងទៅនឹងការដាក់បញ្ចូលឯកសារជាភស្តុតាង ។ មេធាវី ខាណាវ៉ាស់ បានបញ្ជាក់ថា ចំនួននៃសេចក្ដីសម្រេចនេះ គឺបញ្ជាក់ឲ្យឃើញពីការដាក់បញ្ចូលឯកសារ យោងតាមស្ថានភាពជាក់ស្ដែង នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ មេធាវី ខាណាវ៉ាស បានបញ្ចប់ការពិភាក្សាអំពីករណី ដួលីក ដោយបញ្ជាក់ថា ដំណើរការទូទៅដែលប្រើក្នុងករណីនោះគឺដើម្បីពិនិត្យមើលភស្តុតាងនៅទីបញ្ចប់ ជាជាងពិនិត្យមើលកាលពីដំបូងឡើយនៃដំណើរការសវនាការ ហើយតុលាការបានជំទាស់ឯកសារពាប់ពាន់ដើម្បីឲ្យតុលាការអាចគ្រប់គ្រងដំណើរការនោះបាន ។ មេធាវី ខាណាវ៉ាស់ ក៏បានបញ្ជាក់ដែរថា ករណីនេះស៊ីពេលអស់ប្រាំឆ្នាំជាជាងទុកពេលតែពីរឆ្នាំកន្លះនោះ ។

មេធាវីរបស់ អៀង សារី បានបញ្ចប់ដោយបញ្ជាក់ថា «យើងរក្សាជំហររបស់យើងថា មុននិងទទួលយកនូវឯកសារណាមួយ ព្រះរាជអាជ្ញាត្រូវតែបញ្ជាក់អំពីភាពពិត ភាពទុកចិត្តបាននិងការពាក់ព័ន្ធ»របស់ឯកសារនោះជាមុនសិន ហើយ«យើងសូមសំណូរពរថា ឯកសារនោះលើកយកមកនិយាយតែពេលដំណើរការកំពុងតែដំណើរការទៅមុខប៉ុណ្ណោះ» ។ ក្រោយមក មេធាវីការពារក្តី«ហ៊ាន»និយាយថា ព្រះរាជអាជ្ញាត្រូវនាំយកសាក្សីមកជាមួយដើម្បីបញ្ជាក់ពីភាពពិតរាល់ឯកសារទាំងអស់មុននិងដាក់ជាភស្តុតាង ។ ទីបញ្ចប់ មេធាវីប្រឹក្សាបានបញ្ជាក់ថា នោះបីជាការវាយតម្លៃឯកសារអាចធ្វើបានក៏ដោយ ក៏«គ្មានក្បួនដាក់លាក់ណាមួយដែលបានអះអាងថា រាល់ឯកសារទាំងអស់ត្រូវតែអនុញ្ញាតនោះដែរ» ។

## មេធាវីការពារក្តី ខៀវ សំផន ឆ្លើយតបចុងក្រោយទាក់ទងទៅនិងឧបសម្ព័ន្ធ១-៥

មេធាវីការពារក្តី ខៀវ សំផន បានបកស្រាយពីជំហររបស់ខ្លួនមួយចំនួន ។ ទីមួយ មេធាវីការពារក្តីបញ្ជាក់ថា ខ្លួនមិនបានស្នើថា រាល់ឯកសារទាំងអស់គួរតែអាចជឿជាក់បាននោះទេ «លើសពីការសង្ស័យដោយសមស្រប» ជាលក្ខខណ្ឌក្នុងការដាក់បញ្ចូលឯកសារណាមួយនោះទេ ។ តែមេធាវីបានបញ្ជាក់ថា គាត់បានប្រើពាក្យនោះនៅពេលដែលនិយាយពីការបញ្ជាក់ពីភាពពិតរបស់ឯកសារ ជាជាងការសាកល្បងក្នុងការដាក់បញ្ចូលឯកសារ ។ ក្រោយមកមេធាវីប្រឹក្សាបានបញ្ជាក់ថា ខៀវ សំផន មិនបានជំទាស់ផ្ទាត់រាល់ឯកសារទាំងអស់ទេ ពេលដែលគាត់ត្រូវបានសួរដោយព្រះរាជអាជ្ញា ។ មេធាវីប្រឹក្សាបានបញ្ជាក់ថា មានការ«ខុសឆ្គង»ខ្លះចំពោះឯកសារ ជាពិសេសឯកសារដែលយកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខណៈពេលដែលមេធាវីការពារក្តីរបស់ ខៀវ សំផន ជំទាស់ មិនទទួលស្គាល់ឯកសារទាំងអស់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា មេធាវីប្រឹក្សាគ្រាន់តែស្នើថា រាល់ឯកសារទាំងអស់ត្រូវតែ «ពិនិត្យឲ្យបានហ្មត់ចត់» ជាមុនសិនពេលយកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

មេធាវីប្រឹក្សាបានបញ្ជាក់បន្ថែមទៀតថា ខៀវ សំផន មានបំណងស្វែងរក«ការពិត» ហើយដើម្បីធ្វើដូច្នេះ រាល់ឯកសារទាំងអស់ត្រូវតែពិនិត្យមើលឲ្យបានច្បាស់លាស់សិនមុននឹងដាក់បញ្ចូល ។ មេធាវីការពារក្តីបានរក្សាជំហរថា «កិច្ចការរបស់អង្គជំនុំជម្រះ គឺត្រូវពិនិត្យរាល់ឯកសារទាំងអស់ដែលដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះដោយភាគីទាំងអស់ ។

មេធាវីការពារក្តីបានបញ្ជាក់ថា បើសិនជានេះជាកិច្ចការច្រើនពេកសម្រាប់ព្រះរាជអាជ្ញាក្នុងការបញ្ជាក់ឲ្យច្បាស់ពីឯកសារនីមួយៗ មេធាវីសូមចូលទៅមើលភស្តុតាងនោះ ហើយព្រះរាជអាជ្ញាអាចធ្វើបញ្ជីដើម្បីឲ្យអាចគ្រប់គ្រងការងារនោះបានល្អ ។

**អង្គសវនាការបញ្ចប់ដំណើរការ និងបន្តនៅថ្ងៃច័ន្ទ និងចម្លើយតបមេធាវីការពារក្តី នួន ជា**

ក្រោយពីមេធាវីការពារក្តីរបស់ ខៀវ សំផន និយាយចប់ អង្គជំនុំជម្រះបានបញ្ជាក់ថា កម្មវិធីសម្រាប់សប្តាហ៍ក្រោយនឹងផ្ញើរតាមសារអេឡិចត្រូនិចទៅគ្រប់ភាគីទាំងអស់ ហើយពេលនេះ អង្គជំនុំជម្រះបញ្ចប់សម្រាប់ថ្ងៃនេះ ។

តែមុននឹងប្រធានអង្គជំនុំជម្រះប្រកាសបញ្ចប់កម្មវិធី មេធាវីអន្តរជាតិរបស់ នួន ជា ឈ្មោះ ម៉ៃឃើល ផេស្តមែន បានក្រោកឈរហើយបញ្ជាក់ម្តងទៀតថា មេធាវីរបស់ នួន ជា បានច្រានចោលនូវប្រសាសន៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានហៅ នួន ជា ថាជា«ឃាតករ» និងជា «ជនដៃដល់នៃអំពើប្រល័យពូជសាសន៍» ។

ក្រោយពីពិភាក្សាគ្នាមួយសន្ទុះ អង្គជំនុំជម្រះបានបញ្ជាក់ថា មេធាវីរបស់ នួន ជា បាននិយាយពីសំណើនេះរួចមកហើយ ហើយអង្គជំនុំជម្រះសូម«មិនបកស្រាយ»ទាក់ទងទៅនឹងសេចក្តីថ្លែងរបស់នាយករដ្ឋមន្ត្រីនេះទេ អង្គជំនុំជម្រះណែនាំទៅមេធាវីកុំលើកពីបញ្ហានេះមកនិយាយទៀត ។ បន្ទាប់មក អង្គជំនុំជម្រះបានប្រកាសបញ្ចប់សម្រាប់សប្តាហ៍នេះ និងធ្វើការបន្តនីតិវិធីរបស់ខ្លួននៅសប្តាហ៍ក្រោយ ព្រមទាំងមានការធ្វើសក្ខីកម្ម ទៅលើសាក្សីចំនួនពីរនាក់និងមានតំណាងម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការបកស្រាយអំពីបញ្ហាភ័ស្តុតាងនេះ ។

**-ចប់-**